# ការសម្ភាសន៍របស់អ៊ុំស្រី មឹង នាង

កៈ អ្នកសម្ភាសន៍គេមានឈ្មោះ រត្ន ពិសី ខៈ អ្នកដែរត្រូវគេបានសម្ភាសន៍ មឹង នាង

## <u>ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់អ៊ុំស្រី មឹង នាង</u>

កៈ ជាដំបូងខ្ញុំសូមអ៊ុំស្រីខ្ញុំបាទឈ្មោះ រត្ន ពិសី ធ្វើឡើងនៅភូមិបឹងសាឡាង សង្កាត់ ឬស្សីកែវ ភ្នំពេញធ្វើនៅថ្ងៃទី ១០ ខែ ០៥ ឆ្នាំ ២០១៨ខ្ញុំអនុញ្ញាតអ៊ុំស្រីធ្វើការសម្ភាសន៍ជីវប្រវត្តិរបស់អ៊ុំស្រីហើយខ្ញុំធ្វើឡើងដោយសាកលវិទ្យាមួយដែលមានឈ្មោះថា " ប៊ី វ៉ាយ យូវ " ដើម្បីថែរក្សាជីវប្រវត្តិរបស់អ៊ុំស្រីហើយដើម្បីថែរក្សាជីវប្រវត្តិជីដូជីតារបស់អ៊ុំស្រីដើម្បីទុកឲ្យកូនចៅជំនាន់របស់អ៊ុំស្រីឲ្យគាត់បានស្គាល់ពីខ្សែជីវិតរបស់អ៊ុំស្រីថាអ៊ុំមានការលំបាកហើយមានឧបសគ្គអ្វីខ្លះនៅក្នុងជីវិតរបស់អ៊ុំស្រីហើយខ្ញុំធ្វើឡើងនៅថ្ងៃទី ១០ ខែ ០៥ ឆ្នាំ ២០១៨ ។អញ្ចឹងអ៊ុំស្រីមានឈ្មោះអ្វីដែរអ៊ុំស្រី។

ខៈ ខ្ញុំមានឈ្មោះថា មឹង នាង ។

កៈ នៅនិងគេហៅភូមិ សង្ខាត់អ្វីអ៊ុំស្រី?

ខៈ ខ្ញុំទើបតែមកនៅនិង។

កៈ អរ ខ្ញុំបានដឹងមកថានៅភូមិនៅមានឈ្មោះថាភូមិ បឹងសាឡាង សង្ខាត់ ឬស្សីកែវ ខណ្ឌ ឬស្សីកែវ ភ្នំពេញអ៊ុំស្រី។

ខៈ ចាំ!

កៈ អញ្ចឹងអ៊ុំស្រីមានប្រជន្មាប៉ុន្មានដែរអ៊ុំស្រី?

ខៈ ខ្ញុំមានអាយុ៥៨ឆ្នាំ។

កៈ ៥៨ឆ្នាំអ៊ុំណុសអញ្ចឹងអ៊ុំកើតនៅថ្ងៃណាឆ្នាំណាដែរអ៊ុំស្រី?

ខៈ ខ្ញុំអត់ចាំទេព្រោះអីឪពុកម្ដាយរបស់ខ្ញុំគាត់បានស្លាប់បាត់ហើយតាំងពីខ្ញុំនៅតូចមកម្ល៉េះ។

កៈ អត់ទេអ៊ុំហើយអ៊ុំកើតនៅឆ្នាំណាដែរអ៊ុំស្រី?

ខៈ ខ្ញុំអត់ចាំទេ។

កៈ អញ្ចឹងអ៊ុំមាននៅចាំថាអ៊ុំមានឆ្នាំខ្មែរមានឆ្នាំអីដែរ?

ខៈ ឆ្នាំខ្មែរខ្ញុំមានឆ្នាំ ខាល ។

កៈ បាទ! អញ្ចឹងអ៊ុំឆ្នាំ ខាល។ហើយឥឡូវអ៊ុំហាជាងអ៊ុំ។

ខៈ ចាំ!

កៈ បាទ! អញ្ចឹងអ៊ុំកើតនៅឆ្នាំ ១៩៥៦ឬ១៩៥៥និងអ៊ុំ។

ខៈ ចាំ!

កៈ បាទ! អ៊ុំកើតនៅឆ្នាំ១៩៥៥។

ខៈ ចាំ! ចឹងខ្ញុំ៥៦ទេចឹងនោះ។

កៈ បាទ! អញ្ចឹងអ៊ុំមានឈ្មោះហៅខាងក្រៅទេអ៊ុំ?

ខៈ មានគេហៅខាងក្រៅអ៊ុំ ឈិត ។

កៈ អរគេហៅខាងក្រៅគេហៅអ៊ុំ ឈិតៗ ។

ខៈ ចាំ! បើនិយាយពីខ្សែជីវិតខ្ញុំលំបាកណាស់។

កៈ បាទ! ហើយឆ្នាំរបស់អ៊ុំឆ្នាំខាលអ៊ុំ។

ខៈ ចាំ! ឆ្នាំខាល។

កៈ អញ្ចឹងអ៊ុំមានស្រុកកំណើតនៅណាដែរអ៊ុំស្រី?

ខៈ ខ្ញុំនៅខេត្ត ស្វាយរៀង។

កៈ បាទ! អ៊ុំកើតនៅស្វាយរៀងអ៊ុំ។

ខៈ ចាំ!

កៈ ហើយពេលអ៊ុំកើតនិងនៅភូមិស្រុកអីដែរអ៊ុំស្រី?

ខៈ ភូមិយ៉ាងមន្តេញ ។

កៈ ភូមិ យ៉ាងមន្តេញ។

ខ៖ ស្រុករមាលហែក។

ក៖ បាទ!ស្រុករមាលហែក ខេត្តស្វាយរៀងអ៊ុំស្រី។

ខ៖ ចាំ! ខេត្តស្វាយរៀង។

ក៖ ហើយអ៊ុំមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរអ៊ុំស្រី?

ខ៖ ខ្ញុំមានបងប្អូនបង្កើតខ្ញុំសូមរាប់សិនច្រើនណាស់អរ ៩នាក់។

ក៖ បាទ!អញ្ចឹងអ៊ុំមានបងប្អូន៩នាក់អ៊ុំ។

ខ៖ ចាំ!

ក៖ ហើយអញ្ចឹងអ៊ុំកូនទីប៉ុន្មានដែរអ៊ុំស្រី?

ខ៖ ខ្ញុំកូនពៅគេ។

ក៖ អរ អ៊ុំកូនពៅគេអ៊ុំស្រី។

ខ៖ ចាំ!ៗ

ក៖ អញ្ចឹងមាននៅចាំឈ្មោះបងប្អូនរបស់បង្កើតនិងទេអ៊ុំស្រី?

ខ៖ ខ្ញុំចាំតាឈ្មោះបងសួន។

ក៖ បាទ! ហើយចុះទីពីរអ៊ុំ។

ខ៖ ចាំ! ឈប់ច្រើនណាស់។

ក៖ បាទ!

ខ៖ ខ្ញុំអត់ចាំច្បាស់ទេព្រោះអីខ្ញុំនៅតូចៗពេកចឹងខ្ញុំអត់ចាំទេ។

ក៖ បាទ! អ៊ុំនៅតូចៗពេកអ៊ុំស្រី។

ខ៖ ចាំ!ខ្ញុំនៅតូចពេកហើយបងប្អូនច្រើនពេកអត់ថាឈ្មោះអីទេ។

ក៖ បាទ! តែឥឡូវនិងគាត់នៅរស់សព្វថ្ងៃនិងតាអ៊ុំស្រី។

ខ៖ ចាំ! គាត់នៅរស់តា។

កៈ អញ្ចឹងគាត់នៅណាតែឥឡូវនិងអ៊ុំស្រី?

ខៈ
បងប្អូនខ្ញុំមានបងប្អូនមាន៩នាក់ហើយបានស្លាប់អស់២ឥឡូវសល់៧នាក់គាត់នៅមានជីវិតរស់នៅ។

កៈ អរ!ៗ

ខៈ ចាំ!

កៈ ហើយអ្នកស្លាប់នៅគាត់មានឈ្មោះអីដែរអ៊ុំស្រី?

ខៈ បងរត្ន័មួយ។

កៈ ហើយបងប្អូនរបស់អ៊ុំប្រុសប៉ុន្មានស្រីប៉ុន្មានដែរអ៊ុំស្រី?

ខៈ អរស្រីច្រើនណាស់ស្រី៦នាក់ប្រុសតែ៣នាក់។

កៈ បាទ! ប្រុសតែ៣នាក់ទេអញ្ចឹងស្រី៦នាក់អ៊ុំស្រី។

ខៈ ចាំ!

កៈ ហើយដែលស្លាប់២នាក់ស្រីដែរអ៊ុំស្រី។

ខៈ ចាំ! អ្នកដែរស្លាប់និងស្រីមួយប្រុសមួយ។

កៈ ហើយអ្នកដែរនៅរស់គាត់នៅជាមួយអ៊ុំតើអីអ៊ុំស្រី?

ខៈ គេនៅឆ្ងាយៗអស់ហើយ។

កៈ អរ គេនៅឆ្ងាយអស់ហើយអ៊ុំស្រី។

ខៈ ចាំ!
ពួកគេបែកគ្នាតាំងពីជំនាន់សម័យប៉ុលពតមកម្ល៉េះហើយគេយកទៅសម្លាប់ម៉ាពូជៗ។

កៈ អញ្ចឹងស្លាប់អស់ហើយអ៊ុំ។

ខៈ ចាំ! ស្លាប់អស់ហើយ។

កៈ ហើយនៅសល់ដែរអ៊ុំមួយអ៊ុំ។

ខ៖ អត់ទេបងៗខ្ញុំខ្លះគាត់រស់នៅឯស្រុកនិង។

ក៖ នៅសល់ប៉ុន្មាននាក់ដែរអ៊ុំស្រី?

ខ៖ នៅសល់៧នាក់និង។

ក៖ បាទ! នៅសល់ប្រាំពីរនាក់ហើយអ៊ុំមានចាំឈ្មោះពួកគាត់ទេអ៊ុំ?

ខ៖ ខ្ញុំស្គាល់តា។

ក៖ មានឈ្មោះអីគេខ្លះ?

ខ៖ មីគាននិងមួយហើយមីសួរពីរ។

ក៖ ទីប៉ុន្មានដែរអ៊ុំ។

ខ៖ មីសួរនិងពីរហើយមីឡាចនិងបី។

ក៖ បាទ!

ខ៖ មីសុខបួនមីសាន្តប្រាំ។

ក៖ បាទ!

ខ៖ មីគួងមួយហើយមីភាពប្រាំពីរ។

ក៖ បាទ! ហើយអ៊ុំចុងគេបង្អស់អ៊ុំស្រី។

ខ៖ ចាំ! ខ្ញុំពៅគេ។

ក៖ បាទ! អញ្ចឹងអ៊ុំមានចាំសាច់រឿងអ៊ុំនៅពីក្មេងជាមួយពួកគាត់ទេអ៊ុំស្រី?

ខ៖ ខ្ញុំ
នៅតែគេទេខ្ញុំជាក្មេងកំព្រាហើយឪពុកម្ដាយរបស់ខ្ញុំបានស្លាប់តាំងពីខ្ញុំនៅតូចមកម្លេះ។

ក៖ បាទ!

ខ៖ ហើយប៉ុណ្ណឹងហើយក៏នៅជាមួយតែបងនិងហើយ។

ក៖ បាទ!

ខ៖ ហើយឪពុកម្ដាយគាត់ស្លាប់តាំងក្រហមបាតជើងមកម្លេះ។

កៈ បាទ!

ខៈ
ហើយខ្ញុំមានប្រវត្តិម្ដាយខ្ញុំរលាកភ្លើងហើយខ្ញុំអាលាកភ្លើងដែរនិងហើយខ្ញុំមានប្រវត្តិងាប់ដោយសាររលាកភ្លើងហើយដូចម្ដាយខ្ញុំចឹង។

កៈ បាទ!

ខៈ
ហើយខ្ញុំច្រណាំទុកឲ្យឪខ្ញុំមើលហើយគាត់ចាំហើយបងខ្ញុំនិយាយថាមើលតែជើងអូនឯងទៅម៉ែស្លាប់ដោយសារអីហើយគាត់ស្លាប់ដោយសារតែរលាកភ្លើងនិង។

កៈ បាទ!

ខៈ ហើយខ្ញុំបានដឹងហើយខ្ញុំចាំដែលប៉ុណ្ណឹងទេ។

កៈ បាទ!

ខៈ ហើយបើខ្ញុំនិយាយពីប្រវត្តិខ្ញុំវាលំបាកណាស់។

កៈ
ចឹងអ៊ុំតាំងពីតូចរហូតដល់ធំតើអ៊ុំស្រីចូលចិត្តធ្វើអ្វីជាមួយពូកគាត់ទេដូចជាដកស្ទូងធ្វើស្រែចំការទេអ៊ុំស្រី?

ខៈ ដូចជាធ្វើការកាប់អាចម៍គោនិងណា។

កៈ ដូចជាការមើលក្របីទៅចឹងណាអ៊ុំស្រី។

ខៈ ចា៎! ខ្ញុំមើលគោមើលក្របី។

កៈ ហើយអ៊ុំមើលគោមើលក្របីទៅអ៊ុំស្រី។

ខៈ ចា៎! មើលតែក្របីនិងគោនិង។

កៈ បាទ! ហើយមានតែប៉ុណ្ណឹងទេអ៊ុំអត់មានធ្វើអីជាមួយគាត់ទេអ៊ុំស្រី។

ខៈ គ្មានពេលបានសប្បាយទេមានតែលំបាក។

កៈ បាទ!

ខៈ ហើយអត់មានម៉ែលំបាកណាស់។

កៈ បាទ! ហើយឥឡូវពួកគាត់ទៅនៅណាហើយអ៊ុំស្រី?

ខៈ ពួកគាត់ទៅនៅជិតទាល់ដែនថៃឯណុស។

កៈ អូ! គាត់នៅឯជៀងដែនថៃអ៊ុំស្រី?

ខៈ
ខ្លះក៏គាត់នៅនិងខ្លះទៅនៅខាងត្បូនខ្លះទៅហើយមាននៅខាងស្វាយរៀងខ្លះទៅបងប្អូនខ្ញុំនិងខ្ញុំគាត់ដើរនៅគ្រប់ទីកន្លែងនិងពួកគាត់និង។

កៈ
ខ្ញុំនិងមកនៅកំពុងចាមម្នាក់ឯងចឹងទៅហើយអ៊ុំមកនេះអ៊ុំមកលេងកូនអ៊ុំនៅឯភ្នំពេញនិង?

ខៈ
ចាំខ្ញុំមកនិងខ្ញុំមកលេងកូនខ្ញុំនៅភ្នំពេញនិងប៉ុន្មាន់ថ្ងៃទៀតនិងខ្ញុំទៅវិញហើយខ្ញុំនិងនៅមិនបានយូរទេហើយយ៉ាងទៀតខ្ញុំយកកូនពៅខ្ញុំគាត់មកពេទ្យ។

កៈ អ៊ុំហើយម៉ាក់អ៊ុំគាត់មានឈ្មោះអីទៅអ៊ុំ?

ខៈ ម៉ាក់ខ្ញុំគាត់មានឈ្មោះថាយាយឈ្លុសៗ

កៈ គាត់ឈ្មោះលោកយាយឈ្លុសៗ

ខៈ ហើយឪពុកខ្ញុំគាត់ឈ្មោះលោកតាសួង។

កៈ ហើយសព្វថ្ងៃនិងគាត់ទាំងពីរគាត់អាយុប៉ុន្មាន់ហើយអ៊ុំស្រី?

ខៈ
ខ្ញុំអត់បានដឹងផងនិងកាលនិងម៉ាក់ខ្ញុំគាត់បានស្លាប់និងខ្ញុំនៅតាមងពីខ្ញុំបានបីរទឹងនិងកាលនិងចឹងខ្ញុំមិនបានចាំគាត់ទេ។

កៈ អូ!ចឹងលោកឪពុកអ៊ុំគាត់មានអាយុប៉ុន្មាន់ហើយអ៊ុំរាល់ថ្ងៃនិង?

ខៈ អូឪពុកខ្ញុំគាត់អាយុរៀងច្រើនហើយឪពុកខ្ញុំនិងខ្ញុំមិនបានជាចាំទេ។

កៈ ប៉ុន្តែពួកគាត់នៅមានព្រះជុនអីអ៊ុំ?

ខៈ
ពួកគាត់បានស្លាប់អស់ហើយតាំងបីជំនាន់អាពតមកម្លេះហើយអាពតបានយកគាត់ទៅសំ

លាប់តាំងពីរជំនាន់អាពតមកម្លេះនិងចឹងបានជាខ្ញុំមិនបានស្គាល់អាយុឪពុកម្តាយខ្ញុំនិងហើយខ្ញុំនិងជាកូនកំព្រាដើរនៅតែជាមួយម្តាយអ៊ុំម្តាយមីងអីនិងខ្ញុំនិងនោះ។

ក៖ ហើយអ៊ុំមានបានចាំឆ្នាំខ្មែរយើងរបស់ឪពុកម្តាយដែលទេអ៊ុំ?

ខ៖ ខ្ញុំដូចជាមិនបានចាំទេខ្ញុំនិងមកពីខ្ញុំបាន
បែកឪពុកម្តាយខ្ញុំតាមងពីខ្ញុំបាននៅតូចៗមកហើយខ្ញុំ
និងមិនដែលមានអ្នកណាបានប្រាប់ខ្ញុំចឹងខ្ញុំនិងបានដឹងពីអាយុគាត់ហើយឆ្នាំរបស់គាត់ទៀតផងខ្ញុំនិង។

ក៖ ចឹងអ៊ុំមានដែលបានដឹងថាគាត់បានកើតនៅកន្លែងណាដែលទេអ៊ុំ?

ខ៖
ម្តាយឪពុកខ្ញុំគាត់បានកើតនៅស្វាយរៀងនិងនិយាយរួមទៅពួកគាត់ជាអ្នកនៅស្វាយរៀងនិងតែម្តងនិងទាំងតាទាំងយាយរបស់ខ្ញុំទាំងអស់គ្នានៅនិងតែម្តងនិង។

ក៖
អ៊ុំៗមានបានចាំថាកាលពីគាត់បាននៅរស់និងគាត់មានបានប្រកបមុនរបបអីចឹញ្ចឹមអ៊ុំកាលអ៊ុំពីក្មេងដែលអ៊ុំកាលនិង?

ខ៖ ពួកគាត់មិនបានធ្វើអីទេកាលនិងពួកគាត់នៅតែធ្វើតែស្រែចំការនិង។

ក៖ អូចឹងពួកគាត់ជាអ្នកស្រែចំការ?

ខ៖ ម្តាយខ្ញុំនិងឪពុកខ្ញុំ ពួកគាត់អត់មានចំការទេគាត់មានតែស្រែនិងកាលនិង។

ក៖
ចុះបងមានបានដឹងថាឪពុកម្តាយអ៊ុមគាត់ជាមនុស្សបែបណាដែលអ៊ុំសំរាប់អ៊ុំតើគាត់ជាមនុស្សកាចឬក៍ជាមនុស្សល្អហើយជាមនុស្សស្លូតអីចឹងអ៊ុំបានដឹងទេអ៊ុំ?

ខ៖ សំរាប់ម្តាយខ្ញុំអត់បានដឹងទេតែបើឪពុកខ្ញុំ  ខ្ញុំបានដឹងគាត់មិនសូវកាចប៉ុន្មាន់ទេ។

ក៖ អូ!ដឹងគាត់មិនបានកាចទេណាអ៊ុំ?

ខ៖ ចា៎!តែបើបងៗខ្ញុំ ខ្ញុំមិនបានដឹងទេតែមកដល់ខ្ញុំនិងខ្ញុំជាកូនកំព្រាដឹងខ្ញុំនិងបានដឹងទេ។

ក៖បាទ!អ៊ុំអាចនិយាយអំពីរឿងអាពតនិងបានទេថាមានការពិបាកអីខ្លះដែលអ៊ុំកាលនិង?

ខ៖
អូ!ពិបាកណាស់ក្មួយអើយខ្ញុំដើរទៅដេកក្នុងព្រៃនិងហើយខ្ញុំនិងបានដើរទៅដេកក្នុងព្រៃនិងដល់ព្រៃទន្លេសាប់អែលណោះទេខ្ញុំនិងទន្លេធំនៅខាងណោះ។

ក៖ នៅខាងណាដែលអ៊ុំខាងសៀមរាបឬខាងបាត់ដំបង់អែលណោះវិញទេអ៊ុំ?

ខ៖ អត់ទេនៅខាងទន្លេតាប៉ោងអែលណោះទេ។

ក៖ កាលនិងអ៊ុំមានបានចាំថានៅស្រុកណាទេអ៊ុំកាលនិង?

ខ៖
ខ្ញុំអត់ជាបានចាំទេកាតនិងគេជំលៀងទៅៗខ្ញុំមិនបានចាំថាស្រុកណាទេខ្ញុំនិងបើគេអោយយើងដើរតែក្នុងព្រៃនិងចឹងបានខ្ញុំមិនបានចាំនិងណាហើយខ្ញុំនិងបានដេកក្នុងព្រៃខ្ញុំបានលឺអាសត្វព្រៃខឹតៗខ្ញុំបានដេកពីរនាក់បងប្អូនខ្ញុំនៅក្នុងព្រៃនិងទេម្នាក់ឯងហើយខ្ញុំបានដើរពីនាក់បងប្អូនខ្ញុំហើយក័មានគេមានអែងដែលតែកាលនិងគេមិនទាន់យកទៅចោល។

ក៖ បាទ! ដល់ពេលគេត្រូវវាយគេយកទៅវាយទៅ។

ខ៖ ចា៎!
ដូចជាថ្ងៃ២៩គេបាតប្រកាសអញ្ជឹងទៅហើយថ្ងៃ២៨គេយកទៅស្លាប់ហើយអញ្ជឹងណា។

ក៖ បាទ! គេវាយមុនថ្ងៃទៅ។

ខ៖
អត់ទេដូចគេវាយអញ្ជឹងណាហើយគេថាវាយថ្ងៃ៣០និងណាហើយថ្ងៃ២៩គេរំដោះបានអញ្ជឹងទៅ។

ក៖ អញ្ជឹងអ៊ុំបានរួចផុតទៅណាអ៊ុំស្រី។

ខ៖ ចា៎! បានរួចផុតទៅហើយបានរស់នៅទៅណាក្មួយ។

ក៖ បាទ!

ខ៖ បានប៉ុណ្ណឹងហើយរត់មកឆ្ងាយណាស់ហើយវេទនាណាស់ក្មួយអើយៗ
ហើយក្មួយអើយបរទេះដេកតាមថ្នាល់ទេ។

ក៖ បាទ! ហើយអ៊ុំមានការលំបាកអីទៀតទេអ៊ុំស្រី?

ខ៖ ចាំ! ខ្ញុំមានការលំបាកច្រើនណាស់ហើយក៏មានការលំបាកច្រើនណាស់ដែរនៅក្នុងជីវិតរបស់ខ្ញុំនិងហើយខ្ញុំដេកតាមថ្នាល់អញ្ចឹងហើយដេកនិងស្មើរគ្នានិងហើយទំរៀបជួរគ្នានិងហើយពេលនិងមួយខែបានដល់ផ្ទះ។

ក៖ អញ្ចឹងពេលនិងបានហូបអីគ្រប់គ្រាន់ទេអ៊ុំស្រី?

ខ៖ គ្មានអីហូបទេទិញដូរអង្ករគេ។

ក៖ អរ សម័យនិងទិញដូរអង្ករគេអ៊ុំស្រី។

ខ៖ យកមាសហើយយកអីទៅហើយទៅដូរយកអង្ករ។

ក៖ បាទ! ហើយអ៊ុំដូរយកអង្ករយកដំឡូងយកពោតអីទៅអ៊ុំស្រី?

ខ៖ ចាំ! និងហើយដូរយកដំឡូងពោតយកមកស៊ីនិងហើយគ្រាន់មួយពេលៗ ។

ក៖ បាទ! ហើយចែកគ្នាហូបទៅ។

ខ៖ ចាំ! ចែកគ្នាហូបទៅដើរមានអីហូបពេលនិងនោះហើយគ្មានអីហូបស្រុកគេនោះ។

ក៖ បាទ! អញ្ចឹងអ៊ុំមានចាំសាច់រឿងអ៊ុំនៅពីក្មេងទេអ៊ុំជាមួយឪពុកម្ដាយអ៊ុំ។

ខ៖ ចាំសាច់រឿងមិចទៅ?

ក៖ ដូចជាគាត់ទៅណាមានយកអ៊ុំទៅជាមួយទៅជាមួយទៅអ៊ុំស្រី។

ខ៖ គ្មានដែលយកទៅទេគាត់ដើររកស៊ីតែគាត់ទេ។

ក៖ បាទ! គាត់ទៅរកស៊ីតែគាត់ទៅអ៊ុំស្រី។

ខ៖ ហើយពេលគាត់រកបានហើយគាត់មកផ្ទះទៅ។

ក៖ បាទ! ហើយគាត់មកផ្ទះមកហើយអ៊ុំនៅម្នាក់ឯងទៅអ៊ុំស្រី?

ខ៖ ចាំ! ខ្ញុំនៅម្នាក់ឯងតែហើយខ្ញុំនៅជាមួយបងទៅហើយទៅមើលគោមើលក្របីទៅហើយគាត់មកពីរកស៊ីវិញគាត់មកនៅផ្ទះទៅណា។

ក៖ អញ្ចឹងអ៊ុំមាននៅចាំឈ្មោះជីដូនជីតារបស់អ៊ុំស្រីទេ?

ខ៖ ខ្ញុំស្គាល់តែខាងម្ដាយខ្ញុំទេតែបើខាងម្ដាយខ្ញុំអត់ស្គាល់ទេ។

ក៖ បាទ! ហើយអញ្ចឹងខាងម្ដាយមានឈ្មោះអ្វីដែរអ៊ុំស្រី?

ខ៖ ខាងម្ដាយមានឈ្មោះយាយឌុក ។

ក៖ ឈ្មោះយាយឌុកអ៊ុំណុស។

ខ៖ ហើយយាយឌុក។

ក៖ ហើយអ៊ុំមានចាំថាគាត់កើតឆ្នាំណាទេអ៊ុំស្រី?

ខ៖ ហើយស្លាប់យូរហើយ។

ក៖ ហើយឪពុកម្ដាយអ៊ុំគាត់មានប្រាប់អ៊ុំទេអ៊ុំស្រី?

ខ៖ គាត់អត់ប្រាប់ខ្ញុំទេព្រោះខ្ញុំនៅតូចពេកគាត់អត់បានប្រាប់ទេ។

ក៖ បាទ!

ខ៖ អត់ដឹងអីទេព្រោះអីកំព្រាតាំងតូចមកម្លេះហើយ។

ក៖ បាទ!
ហើយអញ្ចឹងអ៊ុំបានប្រាប់ខ្ញុំថាក្រុមគ្រួសារអ៊ុំអ្នកនៅខេត្តស្វាយរៀងទាំងអស់គ្នាទេអ៊ុំស្រី?

ខ៖ ចាំ!

ក៖
អញ្ចឹងអ៊ុំមានបងប្អូននៅក្រៅប្រទេសទេអ៊ុំស្រីដូចជាបងប្អូនជីដូនមួយមានទេអ៊ុំឬក៏ខាងម្ដាយនិងខាងឪពុកទេអ៊ុំស្រី?

ខ៖ អត់មានទេគ្មានបងប្អូនខ្ញុំនៅក្រៅប្រទេសទេក្មួយអើយ។

ក៖ បាទ! ហើយដូចជាបច្ចុប្បន្ននិងអ៊ុំមានបងប្អូនឬក៏ក្មួយអ៊ុំនៅដូចជាប្រទេសកូរ៉េ ថៃ វៀតណាមទេអ៊ុំស្រី?

ខ៖ អត់មានទេ។

ក៖ អត់មានសុទ្ធអ៊ុំស្រី។

ខ៖ ចាំ! ខ្ញុំអត់មានទេបងប្អូននៅប្រទេសគេទេ។

ក៖ បាទ! អញ្ចឹងនៅប្រទេសខ្មែរយើងទាំងអស់អ៊ុំស្រី?

ខ៖ ចាំ!

ក៖
សូមអធ្យាស្រ័យអ៊ុំបើនិយាយអំពីរឿងអាពាហ៍ពិពាហ៍របស់អ៊ុំវិញតើស្វាមីរបស់អ៊ុំមានឈ្មោះអ្វីដែរអ៊ុំស្រី?

ខ៖
ខ្ញុំមិនយកប្តីតែមួយទេខ្ញុំមានប្តីដល់ទៅបីហើយប្តីទីពីរខ្ញុំគាត់ស្លាប់ហើយខ្ញុំយកមួយទៀតទៅនៅតែឪពុកទីបីទេរាល់ថ្ងៃនិង។

ក៖ បាទ!អញ្ចឹងអ៊ុំមានប្តីដល់ទៅបីអ៊ុំស្រី?

ខ៖ ចាំ! ប្តីមុនគាត់ស្លាប់។

ក៖ ហើយប្តីទីមួយគាត់នៅណាដែរអ៊ុំស្រី។

ខ៖ ខ្ញុំលែងគ្នាហើយបានមីមួយនោះហើយបានកូនមួយ។

ក៖ បាទ!

ខ៖ ហើយមកប្តីក្រោយចុងបំផុតនិងឈ្មោះតាឆាយប្តីចុងបំផុតនិង។

ក៖ បាទ! ហើយប្តីទីមួយមានឈ្មោះអ្វីអ៊ុំស្រី?

ខ៖ មានឈ្មោះ អ៊ីង ។

ក៖ ឈ្មោះ អ៊ីងអ៊ុំស្រីហើយប្តីទីពីរមានឈ្មោះអ្វីដែរអ៊ុំ?

ខ៖ ប្តីទីពីរមានឈ្មោះថាតាដួង។

ក៖ ហើយប្តីទីបីមានឈ្មោះតាឆាយអ៊ុំស្រី។

ខ៖ ចាំ!

ក៖ ហើយទីមួយបានកូនប៉ុន្មាននាក់ដែរអ៊ុំស្រី?

ខ៖ បានកូនមួយនិង។

ក៖ ហើយប្តីទីពីរបានប៉ុន្មានដែរអ៊ុំស្រី?

ខ៖ ទីពីរបានបួននាក់។

ក៖ ហើយប្តីទីប្តីបានប៉ុន្មានដែរអ៊ុំស្រី?

ខ៖ ហើយចុងក្រោយនិងបានមួយនិង។

ក៖ បាទ! ចុងក្រោយនិងបានមួយនិងអ៊ុំស្រីហើយអញ្ចឹងកូនអ៊ុំបានប្រាំមួយនាក់អ៊ុំស្រី?

ខ៖ ចាំ!ៗ

ក៖ ហើយអ៊ុំមានស្រីប៉ុន្មានប្រុសប៉ុន្មានដែរអ៊ុំស្រី?

ខ៖ ស្រីបួនប្រុសពីរ។

ក៖ បាទ! ស្រីបួនប្រុសពីរអ៊ុំស្រី។

ខ៖ ចាំ!

ក៖ អញ្ចឹងពួកគាត់មានគ្រួសារអស់ហើយអ៊ុំស្រី?

ខ៖ នៅ។

ក៖ នៅប៉ុន្មាននាក់ដែរអ៊ុំស្រី?

ខ៖ នៅពីរ។

ក៖ នៅពៅគេហើយបន្ទាប់ពៅទៅអ៊ុំស្រី?

ខ៖ ពៅមានប្តីហើយ។

ក៖ អញ្ចឹងពៅមានប្តីហើយ។

ខ៖ បន្ទាប់ពីពៅឡើងមកលើ។

ក៖ អញ្ចឹងបន្ទាប់ពីឡើងមកលើអញ្ចឹងទីពីរទីបីអត់ទាន់មានប្តីហើយអត់ទាន់មានប្រពន្ធ?

ខ៖ ចាំ! ទីបីទីបួនទីប្រាំអត់ទាន់មានទេ។

ក៖ បាទ !ហើយមាននៅជាមួយអ៊ុំឬក៏គេទៅឆ្ងាយហើយ។

ខ៖ គេនៅធ្វើការនៅកោះកុងឯណុស។

ក៖ បាទ!

ខ៖ ដូចនិយាយថាវាមកភ្នំពេញនិងដោយសារទឹកចូលអាស៊ីតភ្នែកនិងណា។

ក៖ បាទ!
ហើយបើនិយាយពីការរៀបអាពាហ៍ពិពាហ៍របស់អ៊ុំរៀបចំពីថ្ងៃណាឆ្នាំណាដែរហើយបានប៉ុន្មានឆ្នាំហើយអ៊ុំស្រី?

ខ៖ ខ្ញុំអត់ដឹងទេនាគ។

ក៖ អត់ចាំទេណាអ៊ុំណុស?

ខ៖ ចា៎! ខ្ញុំអត់ចាំទេកាលនិងការយូរហើយការតាំងពីបែកអាពតមកម្លេះ។

ក៖ បាទ! ហើយបើនិយាយប្តីអ៊ុំទីពីរអ៊ុំ?

ខ៖ ចា៎!

ក៖ ហើយបើប្តីអ៊ុំទីពីរនៅថ្ងៃណាឆ្នាំណាដែរហើយការបានប៉ុន្មានឆ្នាំហើយអ៊ុំស្រី?

ខ៖ អត់ចាំទេ។

ក៖ អត់ចាំដែរអ៊ុំស្រី?

ខ៖ អត់ចាំទេយូរហើយ។

ក៖ ហើយប្តីអ៊ុំចុងក្រោយគេអ៊ុំហើយបានរៀបការនៅថ្ងៃណាដែរអ៊ុំស្រី?

ខ៖ អត់ចាំទេ។

ក៖ អ៊ុំអត់ចាំទាំងអស់។

ខ៖ ខ្ញុំអត់ចាំទេហើយពេលនិងបានត្រឹមសែនទេ។

ក៖ អរ បានត្រឹមសែនទេអ៊ុំស្រី?

ខ៖ ចា៎! ខ្ញុំយកនិងចាស់ហើយនិងពេលខ្ញុំយកនិង។

ក៖ បាទ!

ខ៖ ហើយចាប់ពីប្តីទីពីរមកចាស់អស់ហើយខ្ញុំនិង។

ក៖ បាទ! អញ្ចឹងអ៊ុំអាពាហ៍ពិពាហ៍របស់អ៊ុំនិងដោយអ៊ុំស្រឡាញ់ខ្លួនឯងឬក៏ឪពុកម្តាយអ៊ុំជាអ្នករៀបចំឲ្យអ៊ុំស្រី?

ខ៖ បងស្រីខ្ញុំគាត់អ្នករៀបចំឲ្យ។

ក៖ រៀបចំឲ្យទីមួយនិង។

ខ៖ ចាំ!

ក៖ ហើយរៀបចំឲ្យអញ្ចឹងទៅ។

ខ៖ ចាំ! ខ្ញុំគ្មានឪពុកម្តាយទេហើយនៅតែបងទេហើយបងនិងគាត់ជាអ្នករៀបចំឲ្យនិង។

ក៖ បងគាត់ជាអ្នករៀបចំឲ្យទៅអ៊ុំស្រី?

ខ៖ ចាំ!

ក៖ ហើយបងស្រីបងប្រុសគាត់អ្នករៀបចំឲ្យទៅ។

ខ៖ ចាំ!

ក៖ ហើយប្តីទីពីរអ៊ុំស្រឡាញ់គ្នាឬបងស្រីអ៊ុំគាត់អ្នករៀបចំឲ្យអ៊ុំស្រី?

ខ៖ គេមកសួរត្រឹមត្រូវតាហើយយើងត្រូវគ្នាហើយយើងសែនទៅ។

ក៖ បាទ! គេក៏រៀបចំសែនទៅ។

ខ៖ ចាំ! ក៏រៀបចំសែនទៅ។

ក៖ ហើយអ៊ុំធ្លាប់ឃើញគាត់តាអ៊ុំ។

ខ៖ អត់ដែរស្គាល់ទេទីពីរនិងនោះ។

ក៖ អញ្ចឹងទីពីរនិងអ៊ុំអត់ដែរឃើញទេហើយទីមួយអ៊ុំធ្លាប់ឃើញទេ?

ខ៖ បើទីមួយធ្លាប់ឃើញព្រោះអីនៅស្រុកជាមួយគ្នា។

ក៖ អរនៅស្រុកជាមួយគ្នា។

ខ៖ ចាំ!

កៈ ធ្លាប់ដើរលេងជាមួយគ្នាទៅ។

ខៈ ចាំ!

កៈ ហើយប្ដីទីបីអ៊ុំស្រឡាញ់ដោយខ្លួនឯងឬបងស្រីអ៊ុំគាត់រៀបចំ?

ខៈ រៀបចំដូចគ្នានិងហើយសែនទាំងអស់។

កៈ បានសែនទាំងអស់អ៊ុំ។

ខៈ ចាំ! ហើយគេមកដំណ្ដឹងសួរត្រឹមត្រូវតា។

កៈ ហើយអញ្ចឹងអ៊ុំពេលគាត់មកដំណ្ដឹងអ៊ុំប្ដីទីមួយគាត់ជូនជំនួនប៉ុន្មានដែរ?

ខៈ កាលនិងអត់ទេ។

កៈ អត់ដឹងគាត់ជូនជំនួនប៉ុន្មានទេអ៊ុំ?

ខៈ ពេលនិងអត់ដឹងទេបងខ្ញុំគាត់ជាអ្នករៀបចំឲ្យ។

កៈ អញ្ចឹងអ៊ុំអត់ដឹងទេព្រោះអីបងស្រីអ៊ុំជាអ្នករៀបចំ។

ខៈ ចាំ!

កៈ ហើយប្ដីទីពីរ។

ខៈ ទីពីរគ្មានទេសែនតិចតួចនិង។

កៈ អរ អ៊ុំសែនតិចតួចទៅ។

ខៈ ចាំ!

កៈ ហើយហៅបងប្អូនគាត់មកចូលរួមទៅ។

ខៈ គ្មានផ្ដប់ទេព្រោះអីចាស់ៗហើយបានត្រឹមសែន។

កៈ បាទ! ហើយប្ដីទីបី។

ខៈ ទីបីក៏អញ្ចឹងដែរ។

កៈ បានត្រឹមសែនទៅ។

ខ៖ ពិបាកណាស់អូនអើយយើងអត់មានម្ដាយយើងចេះតែយកទៅ។

ក៖ បាទ!

ខ៖
អញ្ចឹងអ៊ុំអាចប្រាប់ខ្ញុំបានទេពេលដែរបានរៀបការជាមួយប្ដីទីមួយរបស់និងតើអ៊ុំមានបានជួបគ្នាពីមុនមកទេហើយមានធ្លាប់ដើរលេងជាមួយគ្នាពីមុនមកទេអ៊ុំស្រី?

ខ៖ អត់បានជួបគ្នានៅផ្ទះម៉ែឪៗគ្មានបានជួបគ្នាណាទេដូចក្មេងឥឡូវនិងទេ។

ក៖ បាទ!

ខ៖ ដូចបងៗខ្ញុំនិងគាត់ទៅជួបគ្នាទៅហើយគាត់និយាយគ្នាទៅ។

ក៖ អញ្ចឹងអត់បានជួបគ្នាពីមុនទេ?

ខ៖ អត់ទេ។

ក៖ ទីពីរក៏អញ្ចឹងដែរទៅ។

ខ៖ ចាំ!

ក៖ ហើយទីបីបានជួបគ្នា។

ខ៖ ចាំ! ហើយគេមកសួរត្រឹមត្រូវយើងយកទៅ។

ក៖ អរ ទីបីក៏អញ្ចឹងទៅ។

ខ៖ ចាំ!

ក៖ បើនិយាយពីភាសាខ្មែរយើងវិញតើអ៊ុំមានចេះអានហើយចេះសរសេរទេអ៊ុំ?

ខ៖ អត់បានរៀនផង។

ក៖ អ៊ុំស្រីអត់បានរៀនទេ។

ខ៖ ជំនាន់អាពតខ្ញុំគេចាប់ទៅកងច្រលាតអញ្ចឹងខ្ញុំអត់បានរៀនទេ។

ក៖ ពេលនិងអ៊ុំនៅកងច្រលាតនារីពេលនិង។

ខ៖ ចាំ! ពេលនិងកងច្រលាតនារីគេឲ្យបេះបន្លែនិងប្រការនិង។

កៈ ហើយគេឲ្យអ៊ុំកាប់អាចម៍គោកាប់អាចម៍ក្របីអញ្ចឹងទៅអ៊ុំ។

ខៈ ចាំ! ហើយលើកដីគេឲ្យជិកប្រលាយនិង។

កៈ បាទ! ជិកដីអ៊ុំហើយគេឲ្យជិកប្រលាយទៀតអ៊ុំស្រី។

ខៈ ចាំ!

កៈ ហើយអ៊ុំស្រីមាននៅចាំថាប្រលាយនិងមានជម្រៅប៉ុន្មានម៉ែត្រដែរ?

ខៈ ប្រលាយនិងមានជម្រៅប្រហែលពីរម៉ែត្រអូន។

កៈ បាទ!ប្រលាយបណ្តាយប៉ុន្មានម៉ែត្រដែរអ៊ុំ?

ខៈ ប្រលាយនិងឆ្ងាយណាស់ហើយឲ្យដើរលើកប្រលាយដល់ណាដល់នៃអូន។

កៈ បាទ!

ខៈ គ្មានបានរៀនបានសូត្រណា។

កៈ អត់បានរៀនព្រោះគេឲ្យធ្វើការងាររហូតអញ្ចឹងហើយគេឲ្យធ្វើអីធ្វើទៅ។

ខៈ ចាំ! គេឲ្យដកស្ទូងធ្វើស្រែធ្វើចំការនិងហើយទៅធ្វើតាមភូមិទៅ។

កៈ បាទ!

ខៈ យើងនៅកងច្រលាតហើយគេឲ្យធ្វើនៅតាមភូមិនិង។

កៈ បាទ! ហើយបើពីស្រម៉ានអ៊ុំស្រម៉ាននៅតាមអូរនៅនិងទៅ។

ខៈ ចាំ!
ខ្ញុំដេកនៅតាមតងគេហើយតាមមុនអូរនិងទៅ។ហើយគេមានគ្រែកម្ពស់និងណាហើយដេកទំរាប់ជួរគ្នាទៅអញ្ចឹងណានិងក្បែរគ្នាហើយនិង។

កៈ បាទ! ហើយគេងលើគ្នាទៅ។

ខៈ ចាំ! ហើយដេកលើគ្នាទៅណា។

កៈ បាទ!

ខៈ ហើយរូងមួយគ្នាដប់គ្នាទៅ។

កៈ អញ្ចឹងបងពេលនិងអ៊ុំមានអាយុប៉ុន្មានទៅ?

ខៈ ពេលនិងខ្ញុំមានអាយុ១៥ឆ្នាំហើយ។

កៈ ពេលនិងអ៊ុំធំហើយពេលនិង។

ខៈ ចាំ!

កៈ បាទ! ហើយមានជម្រៅប៉ុន្មានម៉ែត្រ?

ខៈ ប្រហែលពីរម៉ែត្រ។

កៈ បាទ! ប្រហែលម៉ែត្រអ៊ុំហើយប្រវែងប៉ុន្មានម៉ែត្រ?

ខៈ អត់ដឹងថាប៉ុន្មានម៉ែត្រទេឆ្ងាយណាស់ពេលនិងខ្ញុំអត់ដឹងទេចេះតែជិកទៅ។

កៈ ហើយចេះតែជិកៗតៗរហូតទេនិងអ៊ុំ។

ខៈ ជិកដល់រហូតដល់ពេលទាល់តែបែកចេញអាពតទើបឈប់ជិក។

កៈ អត់កំណត់ថាប្រវែងណាទេអ៊ុំ។

ខៈ
គេឲ្យជិករហូតដល់ណាទេគេឲ្យជិកពីកន្លែងមួយទៅកន្លែងមួយទៀតរហូតដល់គេឈប់ឲ្យជិកនិង។

កៈ បាទ!

ខៈ គេឲ្យរហូតដល់គេឈប់ឲ្យជីកនិងទៅណា។

កៈ ដឹងថាឆ្ងាយ។

ខៈ ហើយទាល់តែគេប្រាប់ទើបខ្ញុំបានដឹង។

កៈ បាទ!

ខៈ ខ្ញុំអត់ដែរទេយើងកូនចៅគេអូនអើយ។

កៈ បាទ!
អញ្ចឹងអ៊ុំមានមិត្តភក្តិជិតស្និតនៅក្នុងភូមិដែរបានដើរលេងជាមួយគ្នាតាំងពីតូចមកអ៊ុំមានចាំទេ?

ខ៖ មានតាមានបងប្អូនមីងមានពូដើរលេងជាមួយគ្នា។

ក៖ មានតែបងប្អូនអត់មានមិត្តភក្តិទេអ៊ុំស្រី។

ខ៖ អត់ទេខ្ញុំមិនដែរមានមិត្តភក្តិទេ។

ក៖ ហើយបងប្អូនរបស់អ៊ុំមានឈ្មោះអ្វីដែរ?

ខ៖ ពេលធំឡើងជាមួយគ្នានិងបងប្អូនខ្ញុំមានឈ្មោះ អាង ។

ក៖ មានឈ្មោះ អាងហើយពេលនិងអ៊ុំមានប៉ុន្មានគ្នាដែរពេលនិងអ៊ុំស្រី?

ខ៖ មានតែពីរនាក់គ្នានិង។

ក៖ អរ មានតែពីរនាក់ទេអ៊ុំ។

ខ៖ ហើយដើរលេងមីងក្មួយទៅ។

ក៖ ដើរលេងជាមួយគ្នាអញ្ចឹងទៅ។

ខ៖ ដើរលេងជាមួយគ្នាតែពីរនាក់ទៅ។

ក៖ អញ្ចឹងអ៊ុំមានចាំសាច់រឿងជាមួយពួកគាត់ទេអ៊ុំ។

ខ៖
ដើរលេងនៅជិតនិងមានទៅឆ្ងាយទេបានទៅមើលល្ខោនអីទៅពេលមានបុណ្យទានម្តងៗ។

ក៖ បាទ! អញ្ចឹងអ៊ុំដើរលេងមើលល្ខោនជាមួយគ្នា។

ខ៖ ខ្ញុំបានដើរតែពីរនាក់មីងក្មួយនិង។

ក៖ បាទ!

ខ៖ ចាំ!

ក៖ អញ្ចឹងអ៊ុំមាននៅចាំថាគាត់នាំអ៊ុំទៅណាទេអ៊ុំ។

ខ៖ មានទៅណាទេឆ្ងាយទេ។

ក៖ ហើយមាននាំគ្នាទៅរាំទេអ៊ុំស្រី?

ខ៖ ខ្ញុំអត់ចេះរាំទេ។

កៈ អត់ដែររាំទេអញ្ចឹងអ៊ុំចូលចិត្តមើលល្ខោនអ៊ុំស្រី?

ខៈ ចាំ! ខ្ញុំចូលចិត្តមើលល្ខោន។

កៈ
អញ្ចឹងតាំងពីតូចរហូតដល់ធំតើអ៊ុំមានធ្លាប់ធ្វើការស៊ីឈ្នួលគេទេដូចជាការដកស្ទូងធ្វើស្រែធ្វើចំការគេទេអ៊ុំស្រី?

ខៈ ពីតូចខ្ញុំអត់ដែរស៊ីឈ្នួលគេទេពេលដល់ធំទើបខ្ញុំស៊ីឈ្នួលគេឆ្អែកណាស់អូនអើយ។

កៈ តើអ៊ុំធ្លាប់ស៊ីឈ្នួលគេអ្វីដែរអ៊ុំ?

ខៈ
ដកសណ្តែកហើយស្ទូងស្រែចង់ពូកឲ្យគេហើយខ្ញុំមានការចិញ្ចឹមកូនចៅតាំងពីតូចមានការឆ្អែតហើយតាំងពីប្តីខ្ញុំហើយខ្ញុំចិញ្ចឹមកូនតែម្នាក់ឯងទេ។

កៈ ហើយប្តីក្រោយរបស់អ៊ុំនៅមានប្រជន្មារស់នៅតាអ៊ុំស្រី?

ខៈ គាត់នៅមានជីវិតគាត់នៅកំពង់ចាមហើយនៅសួង។

កៈ ហើយគាត់នៅផ្ទះហើយអ៊ុំមកលេងកូនអ៊ុំទៅ។

ខៈ
ដូចខ្ញុំនិយាយថាអញ្ចឹងខ្ញុំមកមើលកូនថាកូនទឹកអាស៊ីតចូលភ្នែកនិងដឹកមកភ្នំពេញនិង។

កៈ បាទ!
អញ្ចឹងអ៊ុំតាំងពីតូចរហូតដល់ធំនិងនៅក្នុងឆាតជីវិតអ៊ុំតើមានការផ្លាស់ប្តូរអ្វីខ្លះនៅក្នុងជីវិតរបស់អ៊ុំដូចជាមានការជួបឧបសគ្គអ្វីខ្លះនៅក្នុងជីវិតរបស់អ៊ុំទេ?

ខៈ អត់សូវសប្បាយមានការលំបាករហូត។

កៈ បាទ!

ខៈ មានការលំបាកណាស់ជួបឧបសគ្គជាច្រើន។

កៈ បាទ!

ខៈ
គ្មានការបានសប្បាយចិត្តទេពេលបានលឺតិចអញ្ចេងតិចអញ្ចុះខ្ញុំគ្មានពេលសប្បាយទេ។

ក៖ បាទ!

ខ៖ សប្បាយអី។

ក៖ ជួបតែឧបសគ្គច្រើនរហូតអ៊ុំស្រី។

ខ៖ ចា៎! ខ្ញុំជួបឧបសគ្គច្រើនណាស់ដូចអូនមើលឃើញហើយ។

ក៖ បាទ!

ខ៖ មានរឿងរហូតកូនបន្តិចទៅហើយចៅបន្តិចទៅមានរឿងរហូតហើយគិតរហូត។

ក៖ បាទ!

ខ៖ គ្មានឲ្យសប្បាយនិងគេទេ។

ក៖ គ្មានការសប្បាយទេអ៊ុំស្រី។

ខ៖ លំបាករហូតនិង។

ក៖ អញ្ចឹងបើនិយាយអំពីម្ហូបវិញតើអ៊ុំចូលចិត្តមុនម្ហូបអ្វីខ្លះ?

ខ៖ បើនិយាយអំពីម្ហូបវិញខ្ញុំចូលចិត្តទាំងអស់និង។

ក៖ ដូចជាសម្លម្ជូលសម្លសម្លឹកហើយនិងកកូរនិងតើអ៊ុំចូលចិត្តទេអ៊ុំ?

ខ៖ ខ្ញុំចូលចិត្តសម្លសម្លឹកសម្លប្រហើរនិងបើម្ជូលខ្ញុំអត់ចូលចិត្តទេ?

ក៖ ហេតុអ្វីបានអ៊ុំអត់ចូលចិត្តសម្លម្ជូលគ្រឿងអ៊ុំស្រី។

ខ៖ ហើយសម្លកកូរនិងណាស់។

ក៖ បាទ! ហើយឆាអ៊ុំចូលចិត្តទេ។

ខ៖ ចា៎! ឆាអីនិងខ្ញុំចូលចិត្តដែរនិង។

ក៖ ហើយឆាអីគេដែរអ៊ុំ?

ខ៖ ដូចជាឆាខ្ញីហើយឆាស្ពៃនិងណាដូចជាស្លម្ជូលសាច់គោអីខ្ញុំអត់ចូលចិត្តទេ។

ក៖ បាទ! អ៊ុំបើនិយាយពីល្បែងប្រជាប្រិយវិញដូចជាល្បែងចោលអង្គុញនិងបោះឈូង លាក់កន្សែងអីតើអ៊ុំចូលចិត្តទេ?

ខ៖ អត់បានទៅលេងជាមួយគេទេ។

ក៖ អ៊ុំនៅតែក្នុងផ្ទះអ៊ុំ?

ខ៖ ចាំ! មានកូនមានចៅហើយបែកពីឆ្នាំ៧៥និងខ្ញុំរៀបការហើយនិង។

ក៖ អរ !

ខ៖ តាំងពីបែក៧៥រហូតមកដល់៧៩មកបងស្រីខ្ញុំគាត់ចាប់ការតែម្តងនិងទៅ។

ក៖
បាទ!ពេលបែកអាពតភ្លាមក៏គាត់ចាប់ការតែម្តងទៅហើយពេលនិងអ៊ុំការនៅអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ ចាំ! ពេលនិងអត់ដឹងថាអាយុប៉ុន្មានពេលនិងខ្ញុំមាន១៨ទៅ២០និង។

ក៖ ពេលនិងអ៊ុំមានអាយុ១៨ឆ្នាំអ៊ុំស្រី។

ខ៖ ចាំ!

ក៖ អញ្ចឹងអ៊ុំចាំថាអ៊ុំការបានប៉ុន្មានឆ្នាំទេអ៊ុំ?

ខ៖ ខ្ញុំអត់ចាំទេថាបានប៉ុន្មានឆ្នាំទេ?

ក៖ បាទ! ហើយអញ្ចឹងអ៊ុំចូលចិត្តរាំទេអ៊ុំស្រី?

ខ៖ ខ្ញុំអត់សូវចូលចិត្តរាំទេ។

ក៖ ហើយបើជាបទចម្រៀងវិញតើអ៊ុំចូលចិត្តចម្រៀងទេ?

ខ៖ ខ្ញុំអត់សូវចូលចិត្តទេ។

ក៖ ហើយបើបទស៊ិម ស៊ីសាម៉តវិញអ៊ុំចូលចិត្តទេ?

ខ៖ ខ្ញុំចូលចិត្តតា។

ក៖ បាទ! ដូចជាអ្នកស្រី ហ៊ឹម ស៊ីវនអីតើអ៊ុំចូលចិត្តទេ?

ខ៖ ចេះតែចូលចិត្តទៅបទចម្រៀងអូន។

ក៖ ហើយចូលចិត្តបទពីដើមៗហើយបើបទសម័យយើងវិញអ៊ុំចូលចិត្តទេ?

ខ៖ ហើយបទពីដើមៗខ្ញុំចូលចិត្តតា។

ក៖ ហើយបើបទពីដើមៗវិញអ៊ុំចូលចិត្តទេអ៊ុំ។

ខ៖ អត់ចង់ស្តាប់ទៅ។

ក៖ បាទ! ហើយអ៊ុំចូលចិត្តបទអីគេខ្លះអ៊ុំ?

ខ៖ ខ្ញុំអត់ចេះរាំហើយអត់ចេះច្រៀងទៀតអត់ដឹងថាបទមួយណាទេ។

ក៖ អត់ចេះទេអ៊ុំ។

ខ៖ អត់ចេះទេបើនៅតែផ្ទះនិង។

ក៖ ហើយអ៊ុំអត់ចូលចិត្តទេអ៊ុំ។

ខ៖ ខ្ញុំអត់ចេះទេបើកូនៗខ្ញុំប្រហែលជាគេចូលចិត្តរាំបើខ្ញុំមិនសូវចូលចិត្តទេ។

ក៖ បាទ!

ខ៖ ខ្ញុំអត់ទេខ្ញុំនៅតែផ្ទះទេមិនបានទៅណាទេ?

ក៖
ហើយបើនិយាយអំពីក្រុមគ្រួសារអ៊ុំវិញឬបងប្អូនរបស់អ៊ុំមានឯណាគេចេះលេងឧបករណ៍តន្ត្រីដូចជាស្គរ ចាប៉ី ទ្រ ហើយមានចេះលេងដូចជាហ្គីតា ព្យាណូទេ?

ខ៖ អត់មានទេ។

ក៖ កូនអ៊ុំអត់ចេះទេអ៊ុំ?

ខ៖ អត់ទេអត់មានអ្នកណាចេះទេ។

ក៖
ហើយបើជានិយាយពីផ្ទះរបស់អ៊ុំតាំងពីតូចរហូតដល់តើផ្ទះរបស់អ៊ុំមានសភាពបែបណាដែរតាំងពីសម័យប៉ុលពតនិងអ៊ុំហើយអ៊ុំមាននៅចាំទេ?

ខ៖ កាលនៅជាមួយម្តាយឪពុកកាលនុង។

ក៖ អញ្ចឹងផ្ទះអ៊ុំប៉ុន្មានខ្នងដែរអ៊ុំ?

ខ៖ ពីរខ្នង។

កៈ បាទ!ពីរខ្នងហើយដំបូល ដំបូលគ្បឿង។

ខៈ ចាំ! ដំបូលគ្បឿង។

កៈ ហើយជញ្ជាំងៗ អីគេដែរ?

ខៈ បើជញ្ជាំងវិញប្រហែលមិនស្គាល់ទេគេហៅឈើកត់។

កៈ អរ ក្ដារកត់និងមែនអ៊ុំ?

ខៈ ចាំ!

កៈ ហើយរណាបវិញរណាបអីដែរ?

ខៈ បើរណាបៗក្ដា។

កៈ រណាបក្ដាយើងនិងអ៊ុំ។

ខៈ រណាបក្ដាយើង។

កៈ ហើយកាំជណ្ដើរវិញកាំជណ្ដើរអីគេអ៊ុំស្រី?

ខៈ កាំជណ្ដើរឈើ។

កៈ បាទ! កាំជណ្ដើរឈើអត់មានកាំជណ្ដើរថ្មទេអ៊ុំ?

ខៈ សម័យនិងគ្មានកាំជណ្ដើរថ្មទេ។

កៈ បាទ! ហើយបើនិយាយអំពីផ្ទះអ៊ុំតើឪពុកម្ដាយអ៊ុំជាអ្នកធ្វើដោយផ្ទាល់ឬក៏គាត់ជួលគេអ៊ុំ?

ខៈ គាត់ធ្វើខ្លួនឯង។

កៈ អរ គាត់ធ្វើខ្លួនឯងផ្ទះដល់តែពីរខ្នងអ៊ុំ។

ខៈ ចាំ! គាត់ធ្វើខ្លួនឯងនិង។

កៈ អញ្ចឹងអ៊ុំមានដឹងថាគាត់ធ្វើបានរយៈពេលប៉ុន្មានខែដែរ?

ខៈ ខ្ញុំដឹងទេតាំងខ្ញុំមិនទាន់កើតមកម្ល៉េះខ្ញុំដឹងទេ។

កៈ បាទ! គាត់អត់បានប្រាប់អ៊ុំនុស។

ខ៖
អត់បានប្រាប់ផងនិងព្រោះម្ដាយឪពុកគាត់បានស្លាប់អស់ហើយបើគាត់នៅរស់អញ្ចឹងបើម្ដាយគាត់នៅរស់គាត់ប្រាប់ហើយ។

ក៖ បាទ! អញ្ចឹងអ៊ុំបានប្រាប់ខ្ញុំគាត់ធ្វើផ្ទះខ្លួនឯង។

ខ៖ ព្រោះពេលនិងគាត់បានប្រាប់ខ្ញុំ។

ក៖ បាទ!

ខ៖ ខ្ញុំអត់ដឹងថាគាត់ធ្វើបានរយៈពេលណាទេ។

ក៖ បាទ! ហើយគាត់មានជំនាញខាងជាងសំណង់ហើយជាងឈើនិងទៅ។

ខ៖ ចាំ! ឪពុកខ្ញុំគាត់ជាងរទេះ។

ក៖ អរ គាត់ជាងរទេះអីអញ្ចឹងទៅ។

ខ៖ ចាំ! គាត់ចេះ។

ក៖ ហើយអញ្ចឹងអ៊ុំមានចេះហើយបន្តវេនពីគ្រួសារអ៊ុំទេដូចជាកូរត្នោត ត្បាញកន្ទេល ក្រមាហើយមានអ៊ុំមានចេះធ្វើស្លឹកត្នោតទេ?

ខ៖ ចេះធ្វើកន្ទេលអីនិងចេះ។

ក៖ ហើយអ៊ុំចេះត្បាញកន្ទេលដែរអ៊ុំហើយអ៊ុំបានបន្តវេនពីគ្រួសារដែរអ៊ុំ?

ខ៖ ខ្ញុំមានចេះបានបន្តពីគ្រួសារគាត់ដែរខ្លះនិង។

ក៖ បាទ!

ខ៖ ហើយខ្ញុំចេះនិងបន្តវេនពីម្ដាយចុងរបស់ខ្ញុំនិង។

ក៖ អ៊ុំមានម្ដាយចុងទៀត។

ខ៖ ចាំ! ហើយម្ដាយចុងខ្ញុំដល់ទៅពីរ។

ក៖ អរ ម្ដាយចុងដល់ទៅពីរអ៊ុំ។

ខ៖ ចាំ!

កៈ
ម្ដាយរបស់អ៊ុំទីបានស្លាប់ហើយម្ដាយទីពីរគាត់ស្លាប់តៗគ្នាទៅហើយយកម្ដាយមួយទៀត។

ខៈ អត់ទេម្ដាយទីមួយគាត់ស្លាប់ហើយម្ដាយទីពីរគាត់លែងគ្នាហើយគាត់យកមួយទៀត។

កៈ បាទ! ហើយទីពីរលែង។

ខៈ ចាំ!

កៈ ហើយអ៊ុំមាក់ទីប៉ុន្មាន់ដែលអ៊ុំ?

ខៈ
ខ្ញុំមានម៉ាក់ទីមួយនិងទីពីរហើយខ្ញុំក៏មានម៉ាទីបីរដែលតែពួកគាត់បានស្លាប់បាត់ហើយពួកគាត់បានស្លាប់នៅជំនាន់អាពតនិង។

កៈ
ចឹងអ្នកមីងមានម្ដាយបង្កើតរបស់អ្នកមីងគាត់បានស្លាប់បាត់ទៅមុនហើយតេក្រោយមកឪពុករបស់អ្នកមីងបានយកម្ដាយពីពីរនិងគាត់បានលែង
តែក្រោយមកគាត់បានស្លាប់នៅជំនាន់អាពតមកម្លេះចុះអ្នកមីងដែលមានស្ដីសង្ឃឹមកាលពីបានរៀននិងអ្នកមីងដែលបានរៀនកាលពីរតូចមកអ្នកមីងបើបានរៀងអ្នកមីងចង់បានក្លាយជាគ្រូពេទ្យ និងគ្រូបង្រៀន
និងការងារអីផ្សេងៗចឹងអ្នកមីងមានបានចង់ក្លាយទៅជាអីផ្សេងៗដូចបំណាងរបស់អ្នកមីងដេលទេអ្នកមីង?

ខៈ ខ្ញុំនិងខ្ញុំចេះតែចឹងដឹងហើយតេខ្ញុំនិងបានរៀនចឹងខ្ញុំចឹងក៏មិនបានសំរាច់ដែលខ្ញុំនិង។

កៈ ចឹងអ្នកមីងមានបានសង្ឃឹមចង់ធ្វើអីទៅដែលការនៅពីក្មេងនិង?

ខៈ
ខ្ញុំចេះតែចង់បានហើយតែខ្ញុំកាលនិងខ្ញុំមិនបានទេមកពីខ្ញុំកាលនិងឪពុកម្ដាយខ្ញុំគាត់នៅក្រចឹងខ្ញុំមិនបានរៀនទេកាលនិងខ្ញុំចឹងបានខ្ញុំមានបំណាងចង់បានអ្វីក៏មិនបានដែលមកពីខ្ញុំមិនបានចេះអក្សរចឹងអោយខ្ញុំធ្វើអីក៏មិនដែលខ្ញុំនិងហើយយ៉ាងទៀតខ្ញុំរស់នៅជាមួយម្ដាយចុងចឹងគ្មានអ្នកណាគេចុងផ្ដើមអោយខ្ញុំបានរៀននិងទេ។

កៈ
បាទមានចឹងហើយអ្នកណាដែលមានម្ដាយចុងចឹងមិនមានអ្នកណាគេចុកផ្ដើមអោយបានរៀនទេការនិង ចឹងអ្នកមីង?

ខ៖ ម្តាយចុងខ្ញុំគាត់អោយខ្ញុំនៅផ្ទះទៅមិនបាច់រៀនទេ។

ក៖
ចឹងអ្នកមីងមិនបានរៀនទេកាលនិងចឹងអ្នកមីងនិងពិបាកហើយអ្នកមីងនៅផ្ទះនៅធ្វើការមិនបាច់ទៅរៀនទេអ្នកមីងចឹងជាចុងក្រោយអ្នកមីងមានអ្វីដែលអ្នកមីងបានផ្តែផ្តាំអោយកូនចៅជំនាន់ក្រោយនិងអោយគាត់បានតាំងចិត្តធ្វើអ្វីដែលល្អហើយកុំអោយធ្វើអីដែលអាក្រក់ណាអ្នកមីងមានអីចង់និយាយទេអ្នកមីង?

ខ៖ ចង់តែខ្ញុំបានប្រាប់កូនខ្ញុំមិនអោយធ្វើអីដែលអាក្រក់ហើយអោយគាត់ខំរៀនទៀត។

ក៖ ចឹងអ្នកមីងបាននិយាយអីអោយល្អអីចឹងអ្នកមីង

ខ៖ ខ្ញុំបាននិយាយអស់ហើយអោយគាត់ខំរៀនមិនបានអោយគាត់ធ្វើអីដែលអាក្រក់ទេ។

ក៖
បាទចឹងអ្នកមីងបានប្រាប់គាត់មិនអោយធ្វើអីពើអីដែលអាក្រក់ទៀតទេអោយគាត់ដើរតាមកន្លងធម៌អីនិងអ្នកមីង?

ខ៖ ចាំខ្ញុំបានប្រាប់គាត់អោយដើរតាមកន្លងធម៌កុមអោយធ្វើអីដែលអាក្រក់។

ក៖ចុះអ្នកមីងអាកូនរបស់អ្នកមីងជៀងរៀងអីទៅអ្នកមីងដូចជាគ្រឿងញៀងអីនិងអ្នកមីង?

ខ៖ និងហើយខ្ញុំមិនបានអោយវាធ្វើចឹងទេតែកូនខ្ញុំមិនដែលអ្វើចឹងទេ។

ក៖
នេះគ្រាន់តែជាពាក្យផ្តែផ្តាំទុកអោយកូនចៅជំនាន់ក្រោយអោយបានដឹងចឹងអ្នកមីងអោយគាត់បានជៀងរៀងរឿងបងធំបងតូកអៅចឹងអ្នកមីង?

ខ៖ ចាំរឿងនិងខ្ញុំបាមនិយាយហើយតែកូនខ្ញុំវាមិនដែលធ្វើចឹងទេ។

ក៖
បាទនេះគ្រាន់តែខ្ញុំចង់អោយអ្នកមីងបានផ្តែផ្តាំអោយកូនចៅជំនាន់ក្រោយបានដឹងអិចឹងអ្នកមីង?

ខ៖ ចាំខ្ញុំចង់ចឹងដែលខ្ញុំមិនចង់អោយគាត់បានធ្វើចឹងទេ។

ក៖ បាទចឹងអ្នកមីងមានអីចង់និយាយទៀតទេអ្នកមីង?

ខ៖ ខ្ញុំអស់ហើយ។

ក៖
ខ្ញុំអរគុណច្រើនដែលអ្នកមីងបានញែកពេលវេលាសំរាប់ខ្ញុំចឹងខ្ញុំអរគុណអ្នកមីងខ្ញុំជំរាប់លាអ្នកមីង។